# ការពិសោធន៍

# ដោយ

# វិធីផ្តិត



KHMER PAP 6/96

## អ្វីទៅការពិសោធន៍ដោយវិធីផ្ទិត?

★ ជារៀងរាល់ឆ្នាំ ស្ថិតិបានបង្ហាញថា ស្ត្រីប្រហែល ១៣,០០០ ស្លាប់ដោយសាររោគមហារីកស្បូន ពីព្រោះតែមិនបានរកឃើញរោគនេះពីដំបូង ។ ស្ត្រីអាស៊ីភាគច្រើន ក៏កើតរោគមហារីកស្បូនដែរ ។

★ ការពិសោធន៍ដោយវិធីផ្ទិត គឺជា ការថតពិនិត្យចំពោះកោសិកាមហារីកនៅលើកស្បូនរបស់អ្នក ។ រោគមហារីកស្បូន អាចកើតឡើងគ្រប់ពេលវេលា ដោយឥតគិតពីអាយុឡើយ ។ រៀងរាល់ឆ្នាំ ការពិសោធន៍ដោយវិធីផ្ទិត ជួយឲ្យរកឃើញរោគមហារីកស្បូនភ្លាមៗ ។ បើសិនជាកើតឡើងភ្លាមៗ រោគនេះស្ទើរតែទាំងអស់ អាចព្យាបាលឲ្យជាបាន។




## របៀបធ្វើការពិសោធន៍ដោយវិធីផ្ទិត:

១-អ្នកនឹងត្រូវប្រាប់ឲ្យឡើងគេងលើគ្រែ ពិនិត្យរោគ

OMH-RC-Knowledge Center
5515 Security Lane, Suite 101
Rockville, MD 20852
1-800-444-6472

ដូចរូបភាពដែលបង្ហាញខាងក្រោមៈ



២-ការពិសោធន៍ដោយវិធីផ្តិត គឺជាការងាយស្រួល និងរហ័ស ។ នៅពេលដែលកំពុងពិសោធន៍ អ្នកគ្រាន់តែសំរួលអារម្មណ៍ ដោយស្រូបខ្យល់ដកដង្ហើមវែងចូលរួចបន្ធូរចេញវិញយឺតៗ ។ កុំខំប្រឹង ព្រោះធ្វើឲ្យសាច់ដុំជុំវិញពោះនិង ប្រដាប់ឡើងតឹង ។

៣-គ្រូពេទ្យនឹងដាក់បញ្ចូលប្រដាប់សំរាប់ពិនិត្យ ទៅក្នុងប្រដាប់ស្ត្រី បន្ទាប់មកប្រើឈើរុំសំឡីផ្តិតយកកោសិកាបន្តិចពីកស្បូន ។ កោសិកាទាំងនោះ នឹងបញ្ជូនទៅមន្ទីរពិសោធន៍ ដើម្បីពិនិត្យមើលរោគមហារីក ឬបញ្ហាដទៃទៀត ។



## តើខ្ញុំគួរតែមានការពិសោធន៍នេះញឹកញាប់ឬទេ?

★ បើសិនជាអ្នករៀបការហើយ(ឬបានរួមដំណេក) អ្នកត្រូវធ្វើការពិសោធន៍ដោយវិធីផ្តិត ក្នុងមួយឆ្នាំម្តង ។

★ អ្នកកាន់តែចាស់ អ្នករិតតែត្រូវការ ការពិសោធន៍នេះ ព្រោះអ្នកអាចកើតជម្ងឺនេះដោយងាយ ។ បើសិនជាអ្នកអាយុចាប់ពី ៦៥ឆ្នាំឡើងទៅ ពិគ្រោះជាមួយគ្រូពេទ្យរបស់អ្នក ។

## ធ្វើការណាត់ជួប ចំពោះការពិសោធន៍ ដោយវិធីផ្តិតឲ្យបានឆាប់!

បើអ្នកមានសំណួរអ្វី ឬត្រូវការជំនួយ សូមទូរស័ព្ទមក ការិយាល័យ កម្មវិធីសុខភាពជនអាស៊ីអគ្នេយ៍ លេខ (៥០៨) ៨៦០-៧៧០០ Ext ៧៩៤០





Family Health and Social Service Center
Southeast Asian Health Program
26 Queen Street
Worcester, MA 01610
860-7700



The Southeast Asian Health Program is funded by the U.S. Department of Health & Human Services, Office of Minority Health (Grant No. D52MP91048-01) and The Massachusetts Department of Public Health, Chronic Disease Prevention Program.



5515 Security Lane, Suite 101
Rockville, MD 20852
1-800-444-6472
mh02D5450